ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ១២១/០៩-ស្តាយ ហាយ (វ៉ននរេច)

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ស្តាយ ហាយ (វ៉ននរេច)**

អាសយដ្ឋាន : ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ២៨៤ ១៦៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក : **អវត្តមាន**

២- ភាគីកម្មករនិយោជិត

ឈ្មោះ : **សហព័ន្ធសហជីព សហជីពយុវជនខ្មែរក្រុមហ៊ុន ស្តាយ ហាយ (វ៉ននរេច)**

អាសយដ្ឋាន : ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១៧ ៣៧០ ៣៦៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក ម៉ៃ វឌ្ឍនា | មន្ត្រីដោះស្រាយវិវាទ KYFTU |
| ២- លោក កែវ សារុំ | តំណាងកម្មករនៃក្រុមហ៊ុន ស្តាយ ហាយ (វ៉ននរេច) |
| ៣- លោក ម៉ៀង ប៉ាន់ | តំណាងកម្មករនៃក្រុមហ៊ុន ស្តាយ ហាយ (វ៉ននរេច) |



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

៤- កញ្ញា ថៃ គីមអួន — តំណាងកម្មករនៃក្រុមហ៊ុន ស្កាយ បាយ ( វិនរេច )

៥- លោក ព្រំ ភាព — កម្មករ

៦- កញ្ញា មឿន សុខុម — កម្មករ

៧- កញ្ញា ជៀវ ជារ៉ុន — កម្មករ

## បញ្ហាក្នុងវិវាទ

( នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា )

១- សូមឱ្យនាយកក្រុមហ៊ុនអនុវត្តលក្ខខណ្ឌការងារ តាមសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ៨១/០៩ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ។

២- សូមឱ្យអនុវត្តកិច្ចព្រមព្រៀង ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៩ ។

៣- សូមបញ្ឈប់ការកាត់ប្រាក់ឈ្នួលម្នាក់ចំនួន ១០០០ រៀល របស់យើងខ្ញុំដោយគ្មានការអនុញ្ញាត និងសុំឱ្យសងរំលឹកឡើងវិញ ចាប់ពីឆ្នាំ២០០៤ ។

៤- សូមឱ្យក្រុមហ៊ុនទទួលយកលោក ម៉ៅ វណ្ណៈ ចូលធ្វើការវិញ ដោយរក្សាកន្លែងការងារនៅដដែល ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ( ខ )( មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ ( អាណត្តិទី៥ ) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ ( ក ) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៨០៥ ក.ប/អក/វ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ។

## សវនាការ និង សន្ទេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទនៃកិច្ចប្រជុំមុនសវនាការ :** ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៩ ( វេលាម៉ោង ០៨:០០ នាទី ព្រឹក ) ។

បញ្ហានៃនីតិវិធី :

នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលលិខិតជូនដំណឹងពីការធ្វើកូដកម្មរបស់សហព័ន្ធសហជីពយុវជនខ្មែរ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩ ស្តីពីការទាមទារឱ្យក្រុមហ៊ុនអនុវត្តតាមសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ៨១/០៩ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ និងកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលលិខិតនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញធ្វើការផ្សះផ្សាវិវាទនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ លើការទាមទារចំនួន ០៤ ចំណុច ប៉ុន្តែការផ្សះផ្សានេះមិនបានទទួលលទ្ធផលសះជានឹងគ្នាលើចំណុចណាមួយទេ។ ចំណុចមិនសះជាចំនួន ០៤ចំណុចនេះបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ០៨:០០ នាទី ព្រឹក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតប្រចាំរោងចក្រមកធ្វើការប្រជុំដើម្បីសាកសួរបន្ថែមជុំវិញពីបញ្ហាវិវាទ ជាពិសេសពីការធ្វើកូដកម្មរបស់កម្មករនិយោជិត។ នៅក្នុងកិច្ចប្រជុំមុនសវនាការនេះ ភាគីកម្មករនិយោជិតបានមានវត្តមានតាមការអញ្ជើញ ចំណែកឯភាគីនិយោជកវិញពុំបានមានវត្តមានតាមកាលបរិច្ឆេទកំណត់ទេ ទោះបីជាភាគីនិយោជកបានទទួលដំណឹងពីការអញ្ជើញនេះ ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលហើយក៏ដោយ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការសាកសួរព័ត៌មានជុំវិញបញ្ហាវិវាទ ទៅភាគីកម្មករនិយោជិតដោយពុំមានវត្តមានរបស់ភាគីនិយោជកឡើយ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចវិវាទនេះ តាមនីតិវិធីច្បាប់ស្តីពីការងារ ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន**

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស្កាយ ហាយ (វិនរេច) លេខ ៨០៥ ក.ប/អក/វ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ស្កាយ ហាយ (វិនរេច) ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្ដល់ព័ត៌មាន លេខ ៥៨៥ កប/អក/វក/លកអ. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្ដល់ព័ត៌មាន លេខ ៥៨៦ កប/អក/វក/លកអ. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្ដាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត

**ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា :**

- តាមការអះអាងរបស់ភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ស្កាយ ហាយ (វ៉នរេច) មានកម្មករនិយោជិតសរុបចំនួនប្រហែល ៣.០០០ នាក់ ហើយដែលក្នុងនោះមានកម្មករនិយោជិតចំនួនប្រហែល ១.៦០៨ នាក់ កំពុងតែធ្វើកូដកម្មនៅមុខក្រុមហ៊ុន។ ប៉ុន្តែបើតាមកំណត់ហេតុរបាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារដែលចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ គឺមានកម្មករនិយោជិតដែលពាក់ពន្ធ័ចំនួន សរុបចំនួនប្រហែល ៣០០ នាក់។

ភាគីកម្មករនិយោជិតបានបញ្ជាក់បន្ថែមទៀតថា ពួកគាត់បានធ្វើលិខិតជូនព័ត៌មានមួយទៅក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្ដីពីការធ្វើកូដកម្មស្របច្បាប់នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ស្ដីពីការទាមទារសុំឱ្យអនុវត្តសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ៨១/០៩-ស្កាយ ហាយ (វ៉នរេច)។

- នៅពេលជួបប្រជុំមុនសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងដូចខាងក្រោម:
  - ចំណុចទាមទារទី ១ គឺទាមទារឱ្យនាយកក្រុមហ៊ុនអនុវត្តលក្ខខណ្ឌការងារតាមសេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ៨១/០៩ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ និងចំណុចទាមទារទី ៤ គឺទាមទារឱ្យក្រុមហ៊ុនទទួលយកលោក ម៉ៅ វណ្ណៈ ចូលធ្វើការវិញ ដោយរក្សាកន្លែងការងារឱ្យនៅដដែល ហើយចំណុចវិវាទនេះត្រូវបានដោះស្រាយនៅក្រុមប្រឹក្សាអជ្ញាកណ្ដាលម្ដងរួចហើយតាមរយៈសេចក្ដីបង្គាប់លេខ ៨១/០៩ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩។ ប៉ុន្តែសេចក្ដីបង្គាប់នោះត្រូវបានភាគីនិយោជកប្ដឹងជំទាស់នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩។ ដោយហេតុនេះហើយទើបកម្មករនិយោជិតបានធ្វើកូដកម្មទាមទារឱ្យភាគីនិយោជកអនុវត្តនៅសេចក្ដីបង្គាប់ ដែលក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានសម្រេចរួចហើយនេះ ។
  - រីឯចំណុចវិវាទទី២ និងចំណុចវិវាទទី៣ នៃសំណុំរឿងលេខ ១២១/០៩ ដូចដែលបានបង្ហាញនៅ

ក្នុងកំណត់ហេតុរបាយការណ៍មិនសះជា ៨០៥ ក.ប/អក/វ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ នោះ ភាគីកម្មករនិយោជិតបានសុំធ្វើការដកចេញតាមរយៈលិខិតចុះថ្ងៃទី០២ ខែសីហា ឆ្នាំ ២០០៩ ដែលចុះហត្ថលេខា ដោយឈ្មោះ ម៉ៃ វឌ្ឍនា, កែវ សារុំ, មៀង ប៉ាន់, ថៃ គីមអួន, មឿន សុខុម, ជៀវ ជារ៉ុន និង ព្រំ ភាព។

## ហេតុផលនៃសេចក្តីសម្រេច

ផ្អែកលើអង្គហេតុខាងលើ ភាគីកម្មករនិយោជិតបានសុំដកការទាមទារចំណុចវិវាទទី២ និងចំណុចវិវាទទី៣ចេញ តាមរយៈលិខិតស្នើសុំដកចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៩ នៅលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដូចនេះ ការទាមទារនៅក្នុងសំណុំរឿងនេះ គឺនៅសល់តែចំណុចវិវាទទី១ និងចំណុចវិវាទទី៤ តែប៉ុណ្ណោះ។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ការទាមទារទាំងពីរនេះ គឺសូមឱ្យនាយកក្រុមហ៊ុនអនុវត្តលក្ខខណ្ឌការងារតាមសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ៨១/០៩ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ដោយក្នុងនោះចំណុចវិវាទទី៤ ក៏មាននៅក្នុងសេចក្តីបង្គាប់លេខ ៨១/០៩ ដែរ។

ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ពួកគេទាមទារសុំឱ្យក្រុមហ៊ុនគោរពសេចក្តីបង្គាប់សំណុំរឿងលេខ ៨១/០៩-ស្កាយ ហាយ (វ៉នរេច) ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩។ ប៉ុន្តែ សេចក្តីបង្គាប់នោះត្រូវបានប្តឹងជំទាស់ដោយភាគីនិយោជក ដូចនេះហើយទើបកម្មករនិយោជិតធ្វើកូដកម្មទាមទារឱ្យភាគីនិយោជកអនុវត្តនៅសេចក្តីបង្គាប់នោះ។

មាត្រា ៣១៩ នៃច្បាប់ស្តីពីការងារបានចែងថា " *សិទ្ធិធ្វើកូដកម្ម និងឡុកអៅ ត្រូវបានធានា។ សិទ្ធិនេះត្រូវបានអនុវត្តដោយភាគីណាមួយក្នុងចំណោមភាគីដែលមានវិវាទ ក្នុងករណីដែលមានការបដិសេធសេចក្តីសម្រេចរបស់អាជ្ញាកណ្តាល* "។

ប្រការ ៤០ កថាខណ្ឌ ២ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ បានចែងថា " *ប្រសិនបើភាគីណាមួយនៃវិវាទ បានដាក់ពាក្យជំទាស់របស់ខ្លួនក្នុងកំឡុងពេលនេះ សេចក្តីបង្គាប់នោះមិនអាចអនុវត្តបានឡើយ។ ក្នុងករណីនេះ បើវិវាទជាវិវាទអំពីសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តបទបញ្ញត្តិនៃច្បាប់ ឧទាហរណ៍: បញ្ញត្តិណាមួយនៅក្នុងច្បាប់ស្តីពីការងារ អនុសញ្ញារួម ឬសេចក្តីបង្គាប់អាជ្ញាកណ្តាលដែលជំនួសអនុសញ្ញារួម) ភាគីវិវាទអាចប្តឹងអំពីករណីនេះទៅតុលាការមានសមត្ថកិច្ចសម្រាប់ការដោះស្រាយចុងក្រោយ* "។

យោងតាមមាត្រា ៣១៩ នៃច្បាប់ស្តីពីការងារ និងប្រការ ៤០ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីមួយ ដែលចង់ឱ្យភាគីម្ខាងទៀត (ដែលបានធ្វើការជំទាស់នឹងសេចក្តីបង្គាប់របស់អាជ្ញាកណ្តាល) អនុវត្តតាមសេចក្តីបង្គាប់ ភាគីនោះអាចប្តឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីសម្រេចដោះស្រាយចុងក្រោយ ឬអាចធ្វើកូដកម្មទៅតាមនីតិវិធីច្បាប់ស្តីពីការងារ (សូម

*មើលសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលលេខ ៨៥/០៦-ស្កតវែរ និងស៊ុបភើពិច្យូ ) ។*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របទៅតាមការបកស្រាយខាងលើនេះដែរ ពោល គឺការទាមទាររបស់កម្មករនិយោជិត ដែលសុំឱ្យនាយកក្រុមហ៊ុន ស្កាយ ហាយ (វ៉នរេច) អនុវត្តន៍សេចក្តី បង្គាប់អាជ្ញាកណ្តាលលេខ ៨១/០៩ ដោយការធ្វើកូដកម្មនេះ គឺជាសិទ្ធិដែលផ្តល់ឱ្យភាគីកម្មករនិយោជិត តាម រយៈមាត្រា ៣១៩ នៃច្បាប់ស្តីពីការងារ និងប្រការ ៤០ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ព្រោះនេះជាការជ្រើសរើសរបស់ពួកគេ ដោយសារខ្លឹមសារនៃបទប្បញ្ញត្តិការងារនេះ បើកសិទ្ធិឱ្យភាគី អាចបន្តបណ្តឹងទៅតុលាការមានសមត្ថកិច្ច ឱ្យភាគីក្រុមហ៊ុនអនុវត្តសេចក្តីបង្គាប់ ឬអាចធ្វើកូដកម្មតាមនីតិវិធី ច្បាប់ ហើយក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតបានជ្រើសរើសយកការធ្វើកូដកម្ម។ ហេតុនេះហើយ ក្រុម ប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនអនុវត្តសេចក្តីបង្គាប់លេខ ៨១/០៩ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ឋិតនៅក្រៅវិសាលភាពយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ១២១/០៩-ស្កាយ ហាយ (វ៉ន រេច) នេះ។

យោងតាមអង្គហេតុ ដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សា អាជ្ញាកណ្តាលសម្រេចដូចតទៅនេះ:

## សម្រេច និង បង្គាប់

- បិទសំណុំរឿងលេខ ១២១/០៩- ស្កាយ ហាយ (វ៉នរេច) ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុំ សុទ្ធី**

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លីវ សុវណ្ណា**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លៈ**

ហត្ថលេខា: ------------------------------------